**LONG BEACH UNIFIED SCHOOL DISTRICT ក្រសួងអប់រំតំបន់ឡុងប៊ីច**

**SERVING LONG BEACH, LAKEWOOD, SIGNAL HILL AND AVALON**

**OFFICE OF THE SUPERINTENDENT ការិយាល័យអគ្គនាយកសាលា**

**1515 HUGHES WAY**
**LONG BEACH, CALIFORNIA 90810-1839**
**(562) 997-8242 • FAX (562) 997-8280**

ថ្ងៃទី២៨ ខែតុលា ឆ្នាំ ២០០៩

សូមជំរាបមកដល់មាតាបិតានិងអ្នកអាណាព្យាបាលសិស្ស:

នៅសប្តាហ៏ក្រោយនេះ ក្រសួងអប់រំតំបន់ឡុងប៊ីចនឹងផ្តល់ទីតាំងឲ្យបើកគ្លីនិកចំនួនពីរកន្លែងសម្រាប់ឲ្យសិស្សទៅចាក់ថ្នាំបង្ការរោគគ្រុនផ្តាសាយ H1N1 (គ្រុនផ្តាសាយជ្រូក) ដោយពុំចាំបាច់បង់ប្រាក់។

**ថ្ងៃពុធ ទី៤ខែវិច្ឆិកា ឆ្នាំ២០០៩**
ម៉ោង៣:០០រសៀល ទៅដល់ ម៉ោង៧:០០យប់
នៅសាលាវិទ្យាល័យ Cabrillo High School
2001 Santa Fe Avenue, Long Beach

**ថ្ងៃព្រហស្បតិ៍ ទី៥ខែវិច្ឆិកា ឆ្នាំ២០០៩**
ម៉ោង៣:០០រសៀល ទៅដល់ ម៉ោង៧:០០យប់
នៅសាលាវិទ្យាល័យ Jordan High School
6500 Atlantic Avenue, Long Beach

គ្លីនិកទាំងពីរនេះនឹងបើកសម្រាប់ឲ្យកុមារអាយុពី៣ឆ្នាំទៅ១៨ឆ្នាំ។ ការចាក់ថ្នាំបង្ការរោគដំណាក់លើកទីដំបូងនេះមានថ្នាំតែមួយចំនួនតូចទេ ប៉ុន្តែយើងសង្ឃឹមថានឹងបានទទួលថ្នាំថែមទៀតនៅប៉ុន្មានសប្តាហ៏ខាងមុខនេះ ហើយយើងបំរុងនឹងបើកទីតាំងគ្លីនិកចាក់ថ្នាំថែមទៀតផងដែរ។ មាតាបិតានៃកុមារដែលមានរោគហឺត ទឹកនោមផ្អែម និងបញ្ហាសុខភាពផ្សេងៗទៀតដែលអាចធ្វើឲ្យងាយនឹងកើតរោគគ្រុនផ្តាសាយ ត្រូវបានលើកទឹកចិត្តដោយមន្ត្រីសុខភាពឲ្យគិតគួរឆ្លៀតឱកាសនេះយកកូនទៅចាក់ថ្នាំបង្ការរោគក្នុងដំណាក់លើកទីដំបូងនេះ។ មាតាបិតាត្រូវតែមកជាមួយកូនហើយចុះហត្ថលេខាលើក្រដាសព្រមព្រៀងមួយច្បាប់ដោយផ្ទាល់។

នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ក្រសួងសុខាភិបាលនិងធនធានមនុស្សប្រចាំក្រុងឡុងប៊ីចនឹងមានបើកគ្លីនិកសហគមន៏ផ្សេងមួយទៀតនៅមជ្ឈ:មណ្ឌលសន្និបាតប្រចាំក្រុងឡុងប៊ីច Long Beach Convention Center ។ កុមារព្រមទាំងមនុស្សពេញវ័យទាំងឡាយអាចទៅចាក់ថ្នាំបង្ការរោគនៅគ្លីនិកនោះ ដែលនឹងបើកសម្រាប់សាធារណ:ជនទូទៅ។ *ក៏ប៉ុន្តែ ចំនួនថ្នាំបង្ការរោគនឹងមានកំរិត។*

សូមកត់ចំណាំថា ក្រសួងអប់រំឡុងប៊ីចពុំមានតំរូវ ឬផ្តល់អនុសាសន៏ឲ្យសិស្សត្រូវតែចាក់ថ្នាំបង្ការរោគនេះទេ។ ក្រសួងអប់រំគ្រាន់តែផ្តល់ទីតាំងឲ្យមានគ្លីនិកទាំងនោះសម្រាប់ជាការងាយស្រួលប៉ុណ្ណោះដល់មាតាបិតាណាដែលចង់ឲ្យកូនចាក់ថ្នាំបង្ការរោគនេះ។ បើលោកអ្នកមានសំនួរអ្វីមួយស្តីអំពីថ្នាំបង្ការរោគនេះ សូមទាក់ទងគ្រូពេទ្យប្រចាំគ្រួសាររបស់លោកអ្នក។

ដើម្បីព័ត៌មានបន្ថែមទៀតអំពីរោគគ្រុនផ្តាសាយ H1N1 សូមចូលទៅវែបសាយ [www.longbeach.gov/health](http://www.longbeach.gov/health) ឬទូរស័ព្ទទៅលេខទូរស័ព្ទពិសេសរបស់រដ្ឋស្តីពីគ្រុនផ្តាសាយ H1N1 (ភាសាអង់គ្លេសនិងអេស្ប៉ាញ៉ុល) នៅលេខ ១-៨៨៨-៨៦៥-០៥៦៤ ពីម៉ោង៨ព្រឹកទៅដល់ម៉ោង៥ល្ងាច ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៏។

សូមអរគុណដល់ការបន្តជួយគាំទ្ររបស់លោកអ្នកមកដល់សាលារៀនយើង។

ដោយសេចក្តីស្មោះចំពោះ

Christopher J. Steinhauser

Christopher J. Steinhauser
អគ្គនាយកសាលារៀន